00384766

E171

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 25 / 09 / 2009
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: [signature]

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**<u>សេចក្តីលម្អិតអំពីការដាក់ជូន</u>**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០១/១៨-០៧-២០០៧-អវតក/អជសង |
| ដាក់ជូន | : | អង្គជំនុំជម្រះសាលាដំបូង |
| កាលបរិច្ឆេទ | : | ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩ |
| ភាគីដាក់ជូនសារណា | : | មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម២) |
| ភាសាដើម | : | ភាសាអង់គ្លេស និង ភាសាខ្មែរ (ការបកប្រែ) |

**<u>ចំណាត់ថ្នាក់</u>**

| | | |
|---|---|---|
| ចំណាត់ថ្នាក់ឯកសារដែលស្នើសុំដោយភាគីដាក់ឯកសារ | : | សាធារណៈ |
| ចំណាត់ថ្នាក់ដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ | : | |
| ស្ថានភាពចំណាត់ថ្នាក់ | : | |
| ការពិនិត្យឡើងវិញលើចំណាត់ថ្នាក់ស្តីទី | : | |
| ឈ្មោះមន្ត្រីកត់ត្រា | : | |
| ហត្ថលេខា | : | |

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 05 / 10 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

# ការដាក់សេចក្តីសន្និដ្ឋាន តាមវិធាន ៩២ នៃវិធានផ្ទៃក្នុង ដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២

---

| **<u>ដាក់ជូនដោយ</u>:** | **<u>ជូនចំពោះ</u>:** |
|---|---|
| **សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី:** | **អង្គជំនុំជម្រះសាលាដំបូង:** |
| លោក ហុង គីមសួន | ចៅក្រម **និល ណុន** ជាប្រធាន |
| លោក គង់ ពិសី | ចៅក្រម Silvia CARTWRIGHT |
| លោក យុង ផានិត | ចៅក្រម **យ៉ា សុខន** |

00384767

E171

លោកស្រី Silke STUDZINSKY

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម **ធូ មណិ**

**ជនជាប់ចោទ:**

លោក កាំង ហ្កេក អ៊ាវ ហៅ "ឌុច"

**មេធាវីការពារក្តីជនជាប់ចោទ:**

លោក ការ សាវុត្ថ

លោក François ROUX

លោកស្រី Marie-Paule CANIZARES

**សហព្រះរាជអាជ្ញា:**

លោកស្រី ជាលាង

លោក William SMITH

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**

លោក គឹម ម៉េងឃី

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី Martine JACQUIN

លោក Philippe CANONNE

លោកស្រី Elizabeth RABESANDRATANA

លោកស្រី Annie DELAHAIE

លោក Pirre-Olivier SUR

កញ្ញា ទី ស្រ៊ីនណា

00384768

E171

លោក Karim A.A. KHAN

លោក Alain WERNER

លោកស្រី Brianne McGONIGLE

លោកស្រី Fabienne TRUSSES-NAPRUS

លោកស្រី Christine MARTINEAU

00384769

E171

## I. ប្រវត្តិ

១- សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង បានផ្អែកលើភស្តុតាងដែលបានរៀបចំនៅចំពោះមុខអង្គជំនុំជម្រះ។ ដើម្បីរួមចំណែកក្នុងការស្វែងរកឱ្យឃើញនូវការពិត សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់ភ្ជាប់ជាមួយនូវភស្តុតាងនានា ដែលភស្តុតាងខ្លះជាភស្តុតាងថ្មី និងភស្តុតាងខ្លះទៀតជាភស្តុតាងដែលមាននៅក្នុងសំណុំរឿងរួចហើយ។

២- ភស្តុតាងដែលបានដាក់ជូនទៅអង្គជំនុំជម្រះនានា បានអនុលោមតាមលក្ខខណ្ឌតម្រូវដូចខាងក្រោម យោងតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ភស្តុតាងទាំងនោះ៖

(i) មានភាពពាក់ព័ន្ធ និងមិនច្រំដែលនោះទេ។

(ii) អាចរកបាន និងបានដាក់ភ្ជាប់ជាមួយ។

(iii) រួមចំណែកសម្រាប់បញ្ជាក់អង្គហេតុ ដែលជាគោលដៅនៃការស្នើសុំបង្ហាញភស្តុតាង។

(iv) ច្បាប់អនុញ្ញាត និង

(v) មិនអូសបន្លាយកិច្ចដំណើរការនីតិវិធី និងមិនមែនមិនសំខាន់នោះទេ។

## II. តម្រូវការបន្ថែម

៣- រយៈពេលស្នើសុំធ្វើបទបង្ហាញអំពីភស្តុតាងដែលអាចទទួលយកបាន នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងរយៈពេលស្នើសុំដាក់ភស្តុតាងនោះនៅចំពោះមុខអង្គជំនុំជម្រះ បានផុតរយៈពេលកំណត់ទៅហើយ។ ភស្តុតាងនានាចុងក្រោយ ត្រូវយកទៅដាក់ជូននៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ ក្រោយពេលដែលសាក្សីនានាដែលគេគិតថានឹងឡើងផ្តល់សក្ខីកម្មមិនបានអញ្ជើញមក ហើយការផ្តល់សក្ខីកម្មផ្សេងៗទៀតបានបញ្ចប់ ឆាប់រហ័សជាងការគិតទុកនោះ។

00384770

E171

៤- ពេលវេលាកំណត់កាលពីលើកមុនត្រូវបានកំណត់សម្រាប់សប្តាហ៍ ដែលចាប់ផ្តើមពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៨។ នោះគឺជាព័ត៌មានដែលមេធាវីអន្តរជាតិបានទទួល និងបានរៀបចំដាក់ភស្តុតាងត្រឹមកាលបរិច្ឆេទនោះដោយយោងតាមព័ត៌មាននោះ។

ផ្អែកតាមអង្គហេតុនានាដូចខាងក្រោម:

(i) មេធាវីអន្តរជាតិក្នុងចំណោមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម២) បានសម្រាកព្យាបាលជំងឺនៅក្នុងមន្ទីរពេទ្យនៅទីក្រុងបាងកក ខណៈពេលដែលត្រូវធ្វើការដាក់សេចក្តីសន្និដ្ឋាននោះ។

(ii) នៅក្នុងចំណោមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម២) មេធាវីអន្តរជាតិមានភារកិច្ចរៀបចំការដាក់សេចក្តីសន្និដ្ឋានទៅលើភស្តុតាងបន្ថែម និងមិនមានបុគ្គលិកជំនួយនៅទីក្រុងភ្នំពេញឲ្យបានគ្រប់គ្រាន់ ដើម្បីជួយរៀបចំការដាក់សេចក្តីសន្និដ្ឋាននោះទេ។

(iii) នៅថ្ងៃទី១៦ និងទី១៧ ខែកញ្ញា ឆ្នាំ២០០៨ ពុំមានការប្រាស្រ័យទាក់ទងគ្នារវាងមេធាវីជាតិ និងមេធាវីអន្តរជាតិអាចធ្វើឡើងបាននោះទេ និង

(iv) ប្រតិចារឹកចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨ អាចបើកមើលបានទាល់តែដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៨ ឯណោះ (ដែលជាថ្ងៃឈប់សម្រាកបុណ្យជាតិ) ពីព្រោះ ការបើកមើលសាររបស់អង្គជំនុំជម្រះវិសាមញ្ញនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៨ មិនអាចធ្វើបានទេ

សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម២) មិនបានដាក់ភស្តុតាង (ខ្លះជាភស្តុតាងថ្មី) តាមការស្នើពីអង្គជំនុំជម្រះសាលាដំបូងតាមពេលវេលាកំណត់ដែល បានតម្រូវត្រឹមថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៨ នោះទេ។

៥- ចំពោះកាលៈទេសៈដែលបានលើកឡើងមួយចំនួនខាងលើ ដែលសហមេធាវីមិនអាចគ្រប់គ្រងបាននេះ យើងខ្ញុំសូមស្នើដល់អង្គជំនុំជម្រះសាលាដំបូងមេត្តាអនុញ្ញាតចំពោះការដាក់សេចក្តីសន្និដ្ឋាននេះ ទោះបីជាកាលបរិច្ឆេទនៃការដាក់សេចក្តីសន្និដ្ឋានបានកន្លងផុតទៅហើយក្តីពីព្រោះថា

ភស្តុតាងមួយចំនួនជាភស្តុតាងមាននៅក្នុងសំណុំរឿង និងភស្តុតាងមួយចំនួនទៀតជាភស្តុតាងថ្មីដែលសំខាន់។

## III. ភស្តុតាង

៦- សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់ជូននូវរូបថតចំនួនបួនសន្លឹកផ្សេងពីគ្នាដែលត្រូវបានស្នើសុំធ្វើជាភស្តុតាង នៅក្នុងពេលផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី ភឹង ហ្គុត ស៊ុនថារី (Phung Guth Sunthary) និងឈានទៅបង្ហាញភស្តុតាងស្តីពីស្ថានភាពសុខភាពជាក់ស្តែងរបស់ឪពុកលោកស្រី គឺលោក ភឹង តុន (Phung Ton)។ ភស្តុតាងនេះត្រូវបានរៀបចំ និងបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដើម្បីរកឱ្យឃើញការពិតពីការធ្វើបាបលោក ភឹង តុន និងស្ថានភាពសុខភាពក្រោយមកទៀត ដែលគាត់មានភាពទន់ខ្សោយ គិតត្រឹមពេលដែលមានការថតរូបនៅមន្ទីរ ស-២១ នោះ០: គាត់ស្គម មានទម្ងន់ទាបជាងទម្ងន់រាងកាយដែលមានសុខភាពល្អ មានភាពទន់ខ្សោយនិងរងការឈឺចាប់ដោយសារកង្វះអាហាររូបត្ថម្ភ។

ឧបសម្ព័ន្ធ ក១ បង្ហាញពីជនរងគ្រោះដែលបានថតរូបនៅក្នុងគុកទួលស្លែង នៅថ្ងៃទី ឬ ប្រហែលជានៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៦។ ឧបសម្ព័ន្ធ ក២ ដល់ ក៤ បង្ហាញពី លោក ភឹង តុន (Phung Ton) មុនពេលឃុំខ្លួន។

៧- ឧបសម្ព័ន្ធ ខ គឺជាការដកស្រង់ចេញមកពីសៀវភៅដែលមានចំណងជើងថា “ពេជ្ឈឃាដបាត់ខ្លួន” ដែលនិពន្ធដោយអ្នកកាសែតនិងអ្នកថតរូបឈ្មោះ Nic Dunlop។ សហព្រះរាជអាជ្ញាកាលពីលើកមុនបានស្នើសុំឱ្យមានការដាក់សៀវភៅ “ពេជ្ឈឃាដបាត់ខ្លួន” នៅចំពោះមុខអង្គជំនុំជម្រះ ទាំងស្រុងតែម្តង។ ទោះបីជាយ៉ាងណាក៏ដោយ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងរឿងនេះកំពុងស្ថិតក្នុងការរង់ចាំនៅឡើយនាពេលនេះ។ ហេតុដូច្នេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមដាក់ជូនជាមួយនេះនូវទំព័រ២៨២ (ផ្នែកទីបីនៃទំព័រនេះ) ទំព័រ២៨៣ និងទំព័រ២៨៤ នៅចំពោះមុខអង្គជំនុំជម្រះ។